ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៥០៥ សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី...ខែ.....ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## ការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យថវិកាស្រុក ខ័ណ្ឌ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥

ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីបទញ្ញថវិការបស់ខេត្ត-ក្រុង
- បានឃើញប្រកាសលេខ ៦០១ ប្រក.សហវ.ហម ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតថវិកាផ្នែកសំរាប់ស្រុក
- បានឃើញសេចក្តីណែនាំលេខ ០០៣១ សហវ.ហម ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការអនុវត្តន៍ថវិកាសំរាប់ស្រុក
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## <u>សំរេច</u>

**<u>ប្រការ</u> ១** : ត្រូវបានដាក់អោយអនុវត្តនូវប្លង់គណនេយ្យទូទៅសំរាប់ថវិកាស្រុក ខណ្ឌ ដែលមានលេខគណនីឈ្មោះ គណនីដូចមានក្នុងឧបសម្ព័ន្ធ ១ និងប្រព្រឹត្តិកម្មនៃគណនីដូចមានក្នុងឧបសម្ព័ន្ធ ២ ដែលភ្ជាប់ជាមួយ ។

**ប្រការ ២ :** គណនេយ្យថវិកាស្រុក ខ័ណ្ឌ ផ្អែកតាមប្រព័ន្ធគណនេយ្យបង្គរ ។ ការអនុវត្តន៍មាតិកាគណនីទាំងនេះ គឺធ្វើជាជំហានៗទៅតាមលទ្ធភាព និង ស្ថានភាពជាក់ស្តែង ។

**ប្រការ ៣ :** រតនាគារជាតិអាចរៀបចំបង្កើតបន្ថែមជាអនុគណនីបន្តរបស់អនុគណនី ដើម្បីបំរើអោយការកត់ត្រាចុះបញ្ជី និងធ្វើរបាយការណ៍ទៅតាមតំរូវការចាំបាច់ ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រកាសនេះចូលជាធរមានចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

*ចំលងជូន :*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## មាតិកាគណនី នៃគណនេយ្យថវិកាស្រុក ខណ្ឌ ឧបសម្ព័ន្ធ ១

| លេខគណនី | | | ឈ្មោះគណនី | កើន | ថយ | សមតុល្យ |
|---|---|---|---|---|---|---|
| **ថ្នាក់ ១ : គណនី** | | | | | | |
| 10 | **មូលធន និងធនបំរុង** | | | | | |
| | 101 | | ទាយជ្ជទាន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 121 | | លទ្ធផលនៃការិយបរិច្ឆេទ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 13 | **ឧបត្ថមកធន-វិនិយោគ** | | | | | |
| | 131 | | ឧបត្ថម្ភកធនទទួលសំភារះបរិក្ខាទ្វេរភាគី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 16 | **បំណុលប្រហាក់ប្រហែល** | | | | | |
| | 164 | | ប្រាក់តំកល់ធានាបានទទួល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 18 | **គណនីទំនាក់ទំនង- ការបែងចែក** | | | | | |
| | 181 | | ការបែងចែកទ្រព្យសម្បត្តិដោយខេត្ត-ក្រុង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **ថ្នាក់ ២ : គណនី អចលកម្ម** | | | | | | |
| 20 | **អចលកម្មអរូបី** | | | | | |
| | 203 | | សោហ៊ុយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 205 | | ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 21 | **អចលកម្មរូបី** | | | | | |
| | 211 | | ដីធ្លី និង ធនធានធម្មជាតិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 212 | | ការរៀបចំកែលំអដីធ្លី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 213 | | សំណង់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2131 | អាគារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2132 | ការរៀបចំកែលំអអាគារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2138 | សំណង់ ផ្សេងៗទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 214 | | ហេដ្ឋារចនាសម្ព័ន្ធ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2141 | បណ្តាញបង្ហូរទឹក និង អនាម័យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2142 | បណ្តាញអគ្គីសនី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2143 | បណ្តាញធារាសាស្ត្រ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2144 | បណ្តាញផ្លូវថ្នល់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 215 | | ឋបនកម្ម បច្ចេកទេស សំភារៈនិង ហត្ថូបករណ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2151 | ឋបនកម្ម បច្ចេកទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2152 | សំភារៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2153 | គ្រឿងឧបករណ៍ ( ហត្ថូបករណ៍ ) | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | 217 | | អចលកម្មដែលបានទទួល គ្រប់គ្រង ប្រើប្រាស់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2171 | ដីធ្លី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2173 | សំណង់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2174 | ហេដ្ឋារចនាសម្ព័ន្ធ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2175 | វប្បនកម្ម បច្ចេកទេស សំភារៈនិង ហត្ថូបករណ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2178 | អចលកម្ម ផ្សេងទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 218 | | អចលកម្មរូបី ផ្សេងទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2181 | សំភារៈ ឧបករណ៍ដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2182 | សំភារៈឧបករណ៍ ការិយាល័យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2183 | សំភារៈព័ត៌មានវិទ្យា និង ទូរគមនាគមន៍ | | | |
| | | 2184 | សង្ហារឹម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 2188 | ផ្សេង ៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 28 | **រំលស់អចលកម្ម** | | | | | |
| | 280 | | រំលស់អចលកម្មអរូបី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 281 | | រំលស់អចលកម្មរូបី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| **ថ្នាក់ ៤ : គណនី តតិយជន** | | | | | | |
| 40 | **អ្នកផ្គត់ផ្គង់** | | | | | |
| | 401 | អ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារ | | | | |
| | | | 401.10 ឆ្នាំនេះ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | | 401.11 ឆ្នាំមុន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 42 | **បុគ្គលិក** | | | | | |
| | 421 | | ប្រាក់បៀវត្ស និង លាភការត្រូវសង | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | | 421.10 ឆ្នាំនេះ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | | 421.11 ឆ្នាំមុន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 422 | | សោហ៊ុយបេសកកម្ម និង សោហ៊ុយផ្សេងៗត្រូវសង | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | | 422.10 ឆ្នាំនេះ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | | 422.11 ឆ្នាំមុន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 45 | **គណនី ទំនាក់ទំនង** | | | | | |
| | 457 | | គណនីទំនាក់ទំនងរវាងថវិកាខេត្ត-ក្រុង និងថវិកាស្រុក | ឥណពន្ធ ឥណទាន | ឥណទាន ឥណពន្ធ | អសមតុល្យ |
| 46 | **ឥណាយិក ឥណទាយី ផ្សេងៗ** | | | | | |
| | 462 | | ប្រាក់តំកល់ធានាលើទីផ្សារសាធារណៈ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 47 | **គណនីចំលង ឬគណនីរង់ចាំ** | | | | | |
| | 470 | | ចំណូលផ្សេងៗរង់ចាំដោះស្រាយ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 472 | | ចំណាយផ្សេងៗរង់ចាំដោះស្រាយ | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | 477 | | រដ្ឋទេយ្យករ ចំណូល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| **ថ្នាក់ ៥ : គណនី ហិរញ្ញវត្ថុ** | | | | | | |
| | 543 | | រដ្ឋទេយ្យករបុរេប្រទាន | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| **ថ្នាក់ ៦ : គណនី ចំណាយ** | | | | | | |
| 60 | **ការទិញ** | | | | | |
| | 601 | | សំភារៈ ផ្គត់ផ្គង់ ថែទាំ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6011 | សំភារៈផ្គត់ផ្គង់សំអាត និង អនាម័យ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6012 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6013 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំ ផ្លូវថ្នល់ ផ្លូវលំ ស្ពាន និង លូ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6014 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6015 | ប្រេងឥន្ធនៈ និង ប្រេងរំអិល | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 602 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6021 | សំភារៈការិយាល័យ និង ការបោះពុម្ព | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6022 | សៀវភៅមើល និង ឯកសារ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6028 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 603 | | ស្បៀងអាហារ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6031 | ស្បៀង | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 604 | | សំលៀកបំពាក់ និង ការតុបតែង | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6041 | ឯកសណ្ឋាន | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6042 | សំលៀកបំពាក់ ការពារសុវត្ថិភាព | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6043 | មេដាយ (គ្រឿងឥស្សរិយយស) | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6048 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 605 | | សំភារៈតូចតាច សង្ហារឹម និង សំភារៈបរិក្ខារ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6051 | សំភារៈ និង បរិក្ខារ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6052 | សង្ហារឹម | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6053 | សំភារៈប្រើប្រាស់ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6058 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 606 | | ថាមពល និង ទឹក | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6061 | អគ្គិសនី | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6062 | ទឹក | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | | 6068 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| | 608 | | សំភារៈផ្គត់ផ្គង់ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណទាយិក |
| 61 | **សេវាខាងក្រៅ** | | | | | |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | ឥណពន្ធ | ឥណទាន | ឥណទាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | 612 | | ការជួលមធ្យោបាយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 613 | | ថ្លៃឈ្នួល និង បន្ទុក ( អសង្ហារឹម ) | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 615 | | ការថែទាំ និងជួសជុល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6151 | ការថែទាំដីធ្លី សួនច្បារ រៀបជាផ្លូវ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6152 | ការថែទាំ ទីផ្សារ សត្តឃាតដ្ឋាន និង អាគារសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6153 | ការថែទាំ ជួសជុល ផ្លូវថ្នល់ ស្ពាន និង ប្រព័ន្ធលូ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6155 | ការថែទាំ និង ជួសជុលឧបករណ៍ សំភារៈការិយាល័យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | | សំភារៈពិតមានវិទ្យា និង ទូរគមនាគមន៍ | | | |
| | | 6156 | ការថែទាំ និង ជួសជុល មធ្យោបាយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6157 | ការថែទាំ និង ជួសជុលសំភារៈឧបករណ៍បច្ចេកទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 616 | | សោហ៊ុយធានារ៉ាប់រង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 617 | | សោហ៊ុយសិក្សាពិសោធន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 618 | | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6181 | សំភារៈនិង ទំនិញ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 62 | **សេវាខាងក្រៅផ្សេងៗ** | | | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 621 | | បុគ្គលិកខាងក្រៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | ឥណពន្ធ | ឥណទាន | ឥណាយិក , |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6213 | បុគ្គលិកសមូលហភាពសាធារណៈផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 622 | | ទំនាក់ទំនងសាធារណៈ និង ការផ្សព្វផ្សាយ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6223 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6224 | សោហ៊ុយពិធីបុណ្យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6225 | ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ ក្នុង និង ក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6226 | សោហ៊ុយសំរាប់ការតាំងពិពណ៌ក្នុង និង ក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6227 | ការឃោសនា និង ផ្សព្វផ្សាយពត៌មានសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 623 | | សោហ៊ុយជាវសារពត៌មាន និង ឯកសារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6241 | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | | 6242 | សោហ៊ុយបេសកកម្ម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6243 | សោហ៊ុយស្នាក់នៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 625 | | ចំណាយទូទាត់សោហ៊ុយ ក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6251 | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6252 | សោហ៊ុយបេសកកម្ម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6253 | សោហ៊ុយស្នាក់នៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរសព្ទ័ តេឡិច និង ទូរសារប្រៃសណីយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 627 | | សោហ៊ុយធនាគារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 628 | | សោហ៊ុយផ្សេង១ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 63 | **ពន្ធ និង អាករ** | | | | | |
| | 631 | | លតាបត្រ័ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 64 | **បន្ទុកបុគ្គលិក** | | | | | |
| | 641 | | លាភការ និងប្រាក់បំណាច់ នៃអំណាចសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6411 | ប្រាក់បំណាច់អភិបាលស្រុក ខ័ណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6412 | ប្រាក់បំណាច់អភិបាលរងស្រុក ខ័ណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6419 | ការសង និង ការបង្វិលវិញ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 642 | | លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខណ្ឌ័អចិន្ត្រៃយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6421 | បៀវត្សមូលដ្ឋាន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6422 | ប្រាក់បំណាច់មុខងារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6424 | ប្រាក់បំណាច់តំបន់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6425 | ប្រាក់បំណាច់ទទួលខុសត្រូវ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6426 | ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6429 | ការសងវិញ និង ការបង្វិលវិញ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 643 | | រង្វាន់ និង ប្រាក់បំណាច់ផ្សេង១ទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6431 | កន្ទ្រាមអាទិភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6432 | ប្រាក់បំណាច់សំរាប់ប្រឡង ប្រឡងប្រជែង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6433 | រង្វាន់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេង១ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6438 | ផ្សេង១ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6439 | ការសង និង ការបង្វិលវិញ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 644 | | លាភការ និងប្រាក់បំណាចបុគ្គលិកមិនមែនក្របខ័ណ្ឌ និង បុគ្គលិកអណ្ដែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6441 | បៀវត្សមូលដ្ឋាន បុគ្គលិកមិនមែនក្របខ័ណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | | 6442 | លាភការផ្សេងៗ ទៀត បុគ្គលិកមិនមែនក្របខ័ណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6443 | ប្រៀវត្សរ៍មូលដ្ឋានបុគ្គលិកអណ្តែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6444 | លាភការផ្សេងៗ ទៀត បុគ្គលិកអណ្តែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6449 | ការសង និង ការបង្វិលវិញ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 645 | | ប្រាក់វិភាជន៍សង្គម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6453 | មរណៈភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6454 | ឧបត្ថម្ភនិវត្តជន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6456 | គ្រោះថ្នាក់ការងារ និងទព្វលភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6457 | ឧបត្ថម្ភឱសថដល់មន្ត្រីរាជការ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6458 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6459 | ការសងវិញ និង ការបង្វិលវិញ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 65 | **ឧបត្ថមកធន និង ជំនួយសង្គម** | | | | | |
| | 651 | | ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6511 | ឧបត្ថម្ភកធនដល់ឃុំ-សង្កាត់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6512 | ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 652 | | ជំនួយសង្គម និងប្រាក់វិភាជន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6521 | ជំនួយដល់ប្រជាជនក្រីក្រសំរាកពេទ្យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6528 | ចំណាយសង្គមផ្សេងៗទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 653 | | ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គម និងវប្បធម៌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6531 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6532 | ឧបត្ថម្ភសហគមន៍កីឡា និងវប្បធម៌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6533 | ឧបត្ថម្ភកាកបាទក្រហម | | | |
| 66 | **បន្ទុកហិរញ្ញវត្ថុ** | | | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 67 | **បន្ទុកពិសេស** | | | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 671 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 675 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 68 | **ទាយជ្ជទានអោយដល់រំលស់អចលកម្ម** | | | | | |
| | 681 | | ទាយជ្ជទានអោយដល់រលស់អចលកម្មអរូបី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 682 | | ទាយជ្ជទានអោយដល់រលស់អចលកម្មរូបី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **ថ្នាក់ ៧ : គណនី ចំណូល** | | | | | | |
| 70 | **ចំណូលសារពើពន្ធ** | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 72 | **ផលខុន នៃ ទ្រព្យសម្បត្តិ រដ្ឋ** | | | | | |
| 73 | **ផលខុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា** | | | | | |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7321 | សេវាសុយោជី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7322 | សេវាសំណង់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7323 | ចំណូលសំរាប់ទំរង់ការរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7324 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7328 | ចំណូលរដ្ឋបាលផ្សេងៗទៀត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 74 | **ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម** | | | | | |
| | 741 | | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 75 | **ការឧបត្ថម្ភកធន** | | | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 751 | | ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិកាខេត្ត-ក្រុង | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 752 | | ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការដ្ឋ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 758 | | ចំណូលឧបត្ថម្ភថវិកាពីប្រភពផ្សេងៗ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 77 | **ផលផ្សេងៗ និងផលពិសេស** | | | | | |
| | 775 | | ផលពីការលក់អចលកម្ម | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 78 | **ការងារនៃរដ្ឋលេខា** | | | | | |

**ឧបសម្ព័ន្ធ ២**

## ប្រព្រឹត្តិកម្មរបស់គណនី នៃ គណនេយ្យថវិកាស្រុក ខណ្ឌ

********

### ១_គណនី ធាតុដើមទុន " លេខ ១០១ " :

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មអរូបី អចលកម្មរូបី ដែលស្រុក ខ័ណ្ឌ មានកន្លងមកហើយបានធ្វើសមាហរ័ណកម្ម ។ តំលៃនៃទ្រព្យសម្បត្តិទាំងនេះ បានមកពីការវាយតំលៃនៅលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ ។

**ការកត់ត្រា :**

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃតំលៃអចលកម្ម រូបី អរូបីដែលបាន ចាត់ទុកជាធនធានរបស់ស្រុក ខ័ណ្ឌ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលជាធនធានរបស់ស្រុក ខ័ណ្ឌនៃតំលៃអចលកម្មមានពីមុនមក ។

**ចំណាំ :** តំលៃអចលកម្មដែលកើតមានក្រោយពីការធ្វើសមាហរ័ណកម្ម គឺត្រូវកត់ត្រាតាមចំនួនទឹកប្រាក់ដែលបាន ទូទាត់ក្នុងពេលទិញ ឬ សាងសង់ទៅក្នុងគណនីអចលកម្ម ដោយមិនប្រើគណនីនេះទេ ។

### ២_គណនី លទ្ធផលនៃការិយបរិច្ឆេទ " លេខ ១២១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាការគណនារកលទ្ធផលនៃការអនុវត្តន៍ថវិកា ចរន្ត ក្នុងការិយបរិច្ឆេទ ដោយផ្ទេរសមតុល្យចុងឆ្នាំពីគណនីចំណូលថវិកាចរន្ត និងគណនីចំណាយថវិកាចរន្តមក ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យឥណាយិកពីគណនី ចំណាយថវិកាចរន្ត

ឥណទាន : កត់ត្រាផ្ទេរសមតុល្យឥណទាយីពីគណនី ចំណូលថវិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញនូវលទ្ធផល អតិរេក នៃការអនុវត្តន៍ថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង

ឥណាយិក បង្ហាញលទ្ធផល ឱនភាព នៃការអនុវត្តន៍ថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង ។

**ចំណាំ :** គណនីនេះត្រូវអសមតុល្យនៅក្រោយពេលចាត់ចែងលទ្ធផលប្រចាំឆ្នាំរួច ។

### ៣_គណនី ឧបត្ថម្ភកធនទទួលសំភារៈបរិក្ខា ទ្វេភាគី " លេខ ១៣១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌបានមកពីការផ្តល់ ឧបត្ថម្ភកធនជាទព្យសំភារៈបរិក្ខាទ្វេភាគី ឬជាសាច់ប្រាក់សំរាប់ទិញ សាងសង់ទ្រព្យសំភារៈ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះនូវឧបត្ថម្ភកធនវិនិយោគដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់វិនិយោគ ដែលបានមកពីការផ្តល់ដោយប្រភពនានា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃ ឧបត្ថម្ភកធនវិនិយោគបូកបន្តដែលបានទទួល ។

**៤-គណនី ប្រាក់តំកល់ធានាបានទទួល " លេខ ១៦៤ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌបានទទួលពីការដំកល់ធានាលើសកម្មភាពអាជីវកម្មរបស់អាជីវករ ក្រុមហ៊ុន ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរចូលគណនីចរន្តគណនីរបស់រតនាគារ ។

**ការកត់ត្រា :**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានសងទៅអាជីវករ ឬ ក្រុមហ៊ុនវិញ

- កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានផ្ទេរទៅជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានទទួលពី អាជីវករ ឬ ក្រុមហ៊ុន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តំកល់ធានាសកម្មភាពអាជីវកម្មដែលពុំទាន់បានសង ។

**ចំណាំ** : គណនីលេខ ១៦៤ ត្រូវបែកទៅជាអនុគណនី ទៅតាមប្រភពដែលបានបង់ប្រាក់ ។

**៥-គណនី ទំនាក់ទំនងការបែងចែកទ្រព្យសម្បត្តិដោយ ខេត្ត-ក្រុង " លេខ ១៨១ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មដែលស្រុក ខ័ណ្ឌបានទទួលពីខេត្តក្រុង និងបានផ្ទេរទៅខេត្ត-ក្រុងវិញ ។ អចលកម្មតែនៅជាកម្មសិទ្ធរបស់ខេត្ត-ក្រុង ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានផ្ទេរប្រគល់ទៅខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានទទួលពីខេត្ត-ក្រុង

សមតុល្យ : ឥណទាយី បង្ហាញតំលៃអចលកម្មសរុបដែលបានទទួល ។

**ចំណាំ** : គណនីលេខ ១៨១ ពុំមានការតាមដានលំអិតទៅតាមអចលកម្មទេ ។

**៦-គណនី សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ " លេខ ២០៣ " :**

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ដែលបានផ្ទេរទៅគណនីអចលកម្មពាក់ព័ន្ធ

សមតុល្យ : ឥណាយិក បង្ហាញតំលៃនៃការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍កំពុងធ្វើ ។

**ចំណាំ** : គណនីលេខ ២០៣ ត្រូវចែកទៅជាអនុគណនី ទៅតាមប្រភេទនៃចំណាយនីមួយៗ ។

### ៧.គណនី ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និង សិទ្ធប្រហាក់ប្រហែល " លេខ ២០៥ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌបានចំណាយដើម្បីបង្កើតឬ ទិញប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែល ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់តំលៃទិញ បង្កើតប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែល

ឥណទាន : កត់ត្រាតំលៃ ប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែលដែលបានជំរះជាមួយគណនីរំលស់ និង គណនីតំលៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬ ជំរះ ។

សមតុល្យ : ឥណាយិក បង្ហាញតំលៃប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែលកំពុងមាន ។

### ៨.គណនី ដីធ្លី និង ធនធានធម្មជាតិ " លេខ ២១១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃដីធ្លី និង ធនធានធម្មជាតិដែលស្រុក ខ័ណ្ឌ បានពីអំណោយ ទិញ និងបានពីរូបភាពផ្សេងទៀត ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ស្រុក ខ័ណ្ឌ

ឥណទាន : កត់ត្រាតំលៃដីធ្លី និង ធនធានធម្មជាតិដែលបានបន្ថយដោយលក់ អំណោយ ឬផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតំលៃដីធ្លីនិងធនធានធម្មជាតិដែលកំពុងគ្រប់គ្រង ។

**ចំណាំ** : តំលៃដីធ្លីពុំមានការគិតរំលស់ឡើយ ។ គណនីលេខ ២១១ អាចចែកជាអនុគណនីទៅតាមប្រភេទដីធ្លី ។

### ៩.គណនី ការរៀបចំ កែលំអដីធ្លី " លេខ ២១២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌបានចំណាយលើការរៀបចំកែលំអដីធ្លី ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលំអដីធ្លី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះជាមួយនឹងទឹកប្រាក់រំលស់ប្តូកបន្ត

សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលំអដីធ្លីពុំទាន់បានជំរះ ។

**១០-គណនី សំណង់ " លេខ ២១៣ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃសំណង់ អាគារដែលស្រុក ខ័ណ្ឌបានទិញ សាងសង់ ឬបានពីអំណោយ ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតំលៃសំណង់ អាគារ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ស្រុក

ឥណទាន : កត់ត្រាតំលៃសំណង់ អាគារដែលបានបន្ថយដោយលក់ ធ្វើអំណោយ ឬ ជំរះ

សមតុល្យ : ឥណពិក បង្ហាញតំលៃសំណង់ អាគារដែលកំពុងមាន ។

**ចំណាំ** :គណនីលេខ ២១៣ត្រូវចែកទៅជាអនុគណនី សំរាប់អាគារ ការរៀបកែលំអអាគារ និងសំរាប់សំណង់ផ្សេងៗ ទៀត ។

**១១-គណនី ហេដ្ឋារចនាសម្ព័ន្ធ " លេខ ២១៤ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធដែលស្រុក ខ័ណ្ឌ បានទិញ សាងសង់ ឬបានពីអំណោយ ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបញ្ចូជាទ្រព្យសម្បត្តិរបស់ស្រុក ខ័ណ្ឌ

ឥណទាន : កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ឬ ជំរះ

សមតុល្យ : ឥណពិក បង្ហាញតំលៃហេដ្ឋារចនាសម្ព័ន្ធដែលកំពុងមាន ។

**ចំណាំ** : គណនីលេខ ២១៤ ត្រូវចែកទៅជាអនុគណនី សំរាប់បណ្តាញបង្ហូរទឹក និង អនាម័យ បណ្តាញអគ្គិសនី បណ្តាញធារាសាស្ត្រ និងសំរាប់បណ្តាញផ្លូវថ្នល់ ។

**១២-គណនី ម៉ាសីនបរិក្ខារ ចក្រកម្មបច្ចេកទេស សំភារៈ និងហត្ថបករណ៍" លេខ ២១៥ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃម៉ាសីនបរិក្ខារ ចក្រកម្មបច្ចេកទេស សំភារៈ ហត្ថបករណ៍ ដែលស្រុក ខ័ណ្ឌ បានពីការទិញ ឬ បានពីអំណោយ ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតំលៃទ្រព្យសម្បត្តិជាម៉ាសីនបរិក្ខារ ចក្រកម្មបច្ចេកទេស សំភារៈ ហត្ថបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិ របស់ស្រុក ខ័ណ្ឌ

ឥណទាន : កត់ត្រាតំលៃ ឋាបនកម្មបច្ចេសទេស សំភារៈ ហត្ថូបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃឋាបនកម្មបច្ចេសទេស សំភារៈ ហត្ថូបករណ៍ដែលកំពុងមាន ។

**ចំណាំ :** គណនីលេខ ២១៥ ត្រូវចែកទៅជាអនុគណនីសំរាប់ឋាបនកម្មបច្ចេកទេស សំភារៈនិងសំរាប់គ្រឿងឧបករណ៍ (ហត្ថូបករណ៍ ) ។

**១៣_គណនី អចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់ " លេខ ២១៧ " :**

គណនីនេះបើកនៅនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូតំលៃអចលកម្មដែលស្រុក ខ័ណ្ឌបានទទួលពីប្រភពផ្សេងមកធ្វើការប្រើប្រាស់ តែនៅជាកម្មសិទ្ធរបស់អ្នកប្រគល់ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង ប្រើប្រាស់

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង ប្រើប្រាស់ហើយបានផ្ទេរចេញវិញ

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មដែលបានទទួល និងកំពុងធ្វើការគ្រប់គ្រង ប្រើប្រាស់ ។

**ចំណាំ :** គណនីលេខ ២១៧ត្រូវចែកទៅជាអនុគណនី សំរាប់ដីធ្លី សំណង់ ហេដ្ឋារចនាសម្ព័ន្ធ ឋាបនកម្មបច្ចេសទេស សំភារៈ និងហត្ថូបករណ៍ និងសំរាប់អចលកម្មបានទទួលមកគ្រប់គ្រងផ្សេងៗទៀត ។

**១៤_គណនី អចលកម្មវត្ថុរូបីផ្សេងទៀត " លេខ ២១៨ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មរូបីផ្សេងទៀតរបស់ស្រុក ខ័ណ្ឌដែលបានទទួលបានពីអំណោយ ទិញ ឬសាងសង់ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មរូបីដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ស្រុក ខ័ណ្ឌ

ឥណទាន : កត់ត្រាតំលៃ អចលកម្មរូបីដែលបានបន្ថយដោយលក់ ផ្តល់ជាអំណោយ ឬជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មរូបីផ្សេងទៀតដែលកំពុងមាន ។

**ចំណាំ :** គណនីលេខ ២១៨ ត្រូវចែកទៅជាអនុគណនី សំរាប់សំភារៈឧបករណ៍ដឹកជញ្ជូន សំភារៈឧបករណ៍ការិយាល័យ សំភារៈពតិមានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម និងសំរាប់អចលកម្មវត្ថុរូបីផ្សេងៗទៀត ។

**១៥_គណនី រំលស់អចលកម្មអរូបី " លេខ ២៨០ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីរបស់ស្រុក ខ័ណ្ឌដែលបានទិញ បានពីអំណោយ និងបានពីឧបត្ថម្ភកធនវិនិយោគ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីដែលបានជំរះជាមួយតំលៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយថវិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់រំលស់អចលកម្មបូកបន្ត ។

**ចំណាំ :** - គណនីរំលស់អចលកម្មអរូបី ត្រូវចែកទៅជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី ៣ នៃគណនីអចលកម្មអរូបី បន្ថែមពីក្រោយលេខ ២៨០ ។

- ការជំរះចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មអរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្ម ស្មើនឹងតំលៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជូទានរំលស់ ។ ការជំរះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់ ។

## ១៦_គណនី រំលស់អចលកម្មរូបី " លេខ ២៨១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី ( លើកលែងដីធ្លី) របស់ ស្រុក ខ័ណ្ឌ បានមកពីការទិញ បានពីអំណោយ ឬបានពីឧបត្ថម្ភកធនវិនិយោគ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីដែលបានជំរះជាមួយតំលៃនៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំ ដោយបានចាត់ទុកជាចំណាយថវិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់បូកបន្ត ។

**ចំណាំ :** - គណនីរំលស់អចលនកម្មរូបី ត្រូវចែកកជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី ៣ ( គណនីអចលកម្មដែលមាន ៣ លេខ ) បន្ថែមពីក្រោយលេខ ២៨១ ឬដោយយកលេខ ២ ខ្ទង់ចុងក្រោយនៃគណនីអចលកម្ម ( គណនីអចលកម្មដែលមានលេខសំគាល់ ៤ លេខ ) បន្ថែមពីក្រោយលេខ ២៨១ ។

- អចលកម្មដែលបានធ្វើរំលស់ស្មើ នឹងតំលៃបញ្ចូល ហើយនៅតែប្រើប្រាស់បាននោះត្រូវបញ្ឈប់ការធ្វើទាយជូទានរំលស់ និងពុំទាន់ជាកម្មវត្ថុនៃការជំរះឡើយ ។

- ការជំរះខាងឥណពន្ធ នៃគណនីរំលស់ យោងទៅតាមការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ការជំរះ ។

## ១៧_គណនី អ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារ " លេខ ៤០១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ដែលបានផ្តល់ទំនិញ សេវាកម្ម និងការងារ យោងតាមអាណត្តិបើកប្រាក់ ឬ បង្វែរពីគណនីផ្សេងមក ។

**ការកត់ត្រា :**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់ជូនអត្ថគាហកៈ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុក ផ្ទេរចូលថវិការដ្ឋ ឬទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវាការងារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅ អត្ថគាហកៈ ។

**ចំណាំ** : - គណនីនេះពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ និងត្រូវចែកទៅជាអនុគណនីសំរាប់បំណុលឆ្នាំចាស់ និង ឆ្នាំថ្មី ។

## ១៨. គណនី ប្រាក់បៀវត្ស និង លាភការត្រូវសង " លេខ ៤២១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិង លាភការដែលត្រូវសងទៅស្រុក ខ័ណ្ឌ និងបានបើកផ្តល់ដោយយោងតាមអាណត្តិបើកប្រាក់ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនប្រាក់បៀវត្ស និងលាភការដែលបានបើកផ្តល់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស និងលាភការដែលត្រូវបើកផ្តល់ជូន ស្រុក ខ័ណ្ឌ

សមតុល្យ : ឥណទាយី បង្ហាញចំនួនប្រាក់បៀវត្ស និងលាភការដែលពុំទាន់បានបើកផ្តល់ជូនស្រុក ខ័ណ្ឌ ។

**ចំណាំ** : គណនីលេខ ៤២១ មានគំរូហត្ថលេខារបស់ម្ចាស់គណនី ដែលជាភ្នាក់ងារបើកផ្តល់ ហើយត្រូវចែកទៅជាអនុគណនីសំរាប់ឆ្នាំចាស់ និងឆ្នាំថ្មី ។

## ១៩. គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេង ៗ ត្រូវសង " លេខ ៤២២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និង សោហ៊ុយផ្សេង១ទៀតដែលត្រូវសងទៅស្រុក ខ័ណ្ឌ តាមរយៈភ្នាក់ងារបើកផ្តល់ ឬរជ្ជទេយ្យករបុរេប្រទាន ដោយយោងតាមអាណត្តិបើកប្រាក់ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេង១ ដែលបានបើកផ្តល់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ សោហ៊ុយបេសកកម្ម និង សោហ៊ុយផ្សេង១ដែលត្រូវបើកផ្តល់ជូនស្រុក ខ័ណ្ឌ ។

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលប្រាក់ សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេង១ដែលពុំទាន់បានបើកផ្តល់ជូន ស្រុក ខ័ណ្ឌ ។

**ចំណាំ** : គណនីលេខ ៤២២ ពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនី ហើយត្រូវចែកជាអនុគណនី សំរាប់ឆ្នាំចាស់ និងឆ្នាំថ្មី ។

**២០-គណនី ទំនាក់ទំនងរវាងថវិកាខេត្ត-ក្រុង និង ថវិកាស្រុក ខ័ណ្ឌ " លេខ ៤៥៧ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយថវិកាស្រុក ខ័ណ្ឌ តែមានការពាក់ព័ន្ធរួមជាមួយគណនីប្រាក់បញ្ញើរបស់ថវិកាខេត្ត-ក្រុង ។

**ការកត់ត្រា :**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ ស្មើនឹងចំណូលថវិការបស់ស្រុកដែលពាក់ព័ន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

- កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិការបស់ស្រុកដែលពាក់ព័ន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិការបស់ស្រុកដែលពាក់ព័ន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

- កត់ត្រាចំនួនទឹកប្រាក់ ស្មើនឹងចំណូលថវិការបស់ស្រុកដែលពាក់ព័ន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

សមតុល្យ : អសមតុល្យ ។

**ចំណាំ** : គណនីលេខ ៤៥៧ ជាគណនីចំលង និង បង្ហាញអំពីទំនាក់ទំនងជាមួយគណនីប្រាក់បញ្ញើថវិកាខេត្ត-ក្រុង ដែលប្រើរួមគ្នាជាមួយស្រុក ខ័ណ្ឌ ។

**២១-គណនី ប្រាក់តំកល់ធានាលើទីផ្សារសាធារណៈ " លេខ ៤៦២ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការបានបង់សំរាប់ដំកល់ធានាការដេញថ្លៃលើការផ្គត់ផ្គង់សំភារៈ សេវាកម្ម ដល់ស្រុក ខ័ណ្ឌ ដោយយោងតាមកិច្ចសន្យា ។

**ការកត់ត្រា :**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាលើទីផ្សារសាធារណៈដែលបានសងទៅអ្នកដែលបានបង់ប្រាក់តំកល់ធានា

- កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាលើទីផ្សារដែលបានផ្ទេរជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាលើទីផ្សារដែលបានបានទទួល

សមតុល្យ : ឥណទាយី ឆ្លុះបញ្ចាំងចំនួនទឹកប្រាក់តំកល់ធានាលើទីផ្សារសាធារណៈដែលត្រូវសង ។

**ចំណាំ** : - គណនីនេះត្រូវចែកទៅជាអនុគណនីលំអិតសំរាប់តាមដានទៅតាមអង្គភាព ទទួលការផ្គត់ផ្គង់

- នៅពេលដកប្រាក់តក់ទៅវិញ ស្រុក ខ័ណ្ឌត្រូវចេញលិខិតបញ្ជាក់មក រតនាគារដើម្បីបើកផ្តល់ប្រាក់ ។

**២២-គណនី ចំណូលផ្សេងៗរង់ចាំដោះស្រាយ " លេខ ៤៧០ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែល

ស្រុក ខ័ណ្ឌ ត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត ។ គណនីលេខ ៤៧០ ជាគណនីចំលង ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការដោះស្រាយ ។

**ចំណាំ** : គណនីលេខ ៤៧០ ត្រូវចែកទៅជាអនុគណនីទៅតាមប្រភពចំណូលនីមួយៗ ។

**២៣-គណនី ចំណាយផ្សេងៗ រង់ចាំដោះស្រាយ " លេខ ៤៧២ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយផ្សេងៗ ដែលស្រុក ខ័ណ្ឌ ត្រូវធ្វើនិយ័ត្តកម្ម។ គណនីលេខ ៤៧២ ជាគណនីចំលង ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ ។

**ចំណាំ** : គណនីលេខ ៤៧២ ត្រូវចែកជាអនុគណនីទៅតាមមុខសញ្ញាចំណាយនីមួយៗ ។

**២៤-គណនី រដ្ឋលេយ្យករចំណូល " លេខ ៤៧៧ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋលេយ្យករ ចំណូលរបស់ស្រុក ខ័ណ្ឌ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនប្រាក់ដែលរដ្ឋលេយ្យករចំណូលបានផ្ទេរចូលថវិកា

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូល ដែលរដ្ឋលេយ្យករបានបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនប្រាក់ដែលរដ្ឋលេយ្យករចំណូលពុំទាន់បានផ្ទេរចូលថវិកាស្រុក ។

**ចំណាំ** : គណនីលេខ ៤៧៧ ត្រូវមានគំរូហត្ថលេខារបស់រដ្ឋលេយ្យករ ។

**២៥-គណនី រដ្ឋលេយ្យករបុរេប្រទាន " លេខ ៥៤៣ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលរតនាគារខេត្ត-ក្រុង បានផ្តល់ទៅរដ្ឋលេយ្យករបុរេប្រទាន ស្រុក ខ័ណ្ឌ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទាន

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាអាណត្តិបើកប្រាក់

- កត់ត្រាចំនួនប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ។

**ចំណាំ** : - ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន គឺត្រូវធ្វើនៅក្រៅកិច្ចបញ្ជីការគណនេយ្យ

- គណនី លេខ ៥៤៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

**២៦-គណនី ទិញសំភារៈផ្គត់ផ្គង់ថែទាំ " លេខ ៦០១ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការទិញសំភារៈផ្គត់ផ្គង់ ថែទាំ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០១ ត្រូវចែកទៅជាអនុគណនីសំរាប់ចំណាយទិញសំភារៈផ្គត់ផ្គង់សំអាត និងអនាម័យ សំភារៈផ្គត់ផ្គង់ថែទាំអាគារ សំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ និងសំរាប់ទិញប្រេងឥន្ធនៈ និងប្រេងរំអិល ។

**២៧-គណនី ទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល " លេខ ៦០២ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ស្រុក ខ័ណ្ឌលើការទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០២ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញសំភារៈការិយាល័យ និង ការបោះពុម្ព ទិញសៀវភៅមើល និងឯកសារ និង សំរាប់ទិញសំភារៈផ្សេងៗ ។

**២៨_គណនី ទិញស្បៀងអាហារ " លេខ ៦០៣ " :**

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនទឹកប្រាក់ចំណាយថវិកា ស្រុក ខ័ណ្ឌលើការទិញស្បៀង ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០៣ ត្រូវចែកជាអនុគណនី សំរាប់ទិញស្បៀង ។

**២៩_គណនី ទិញសំលៀកបំពាក់ និងការតុបតែង " លេខ ៦០៤ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការទិញសំលៀកបំពាក់ ឯកសណ្ឋាន សំលៀកបំពាក់ការពារសុវត្ថិភាព ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០៤ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញឯកសណ្ឋាន សំលៀកបំពាក់ការពារសុវត្ថិភាព មេដាយ ( គ្រឿងឥស្សរយយស ) និង ទិញសំលៀកបំពាក់ និង ការតុបតែងផ្សេងៗ ។

**៣០_គណនី ទិញសំភារៈតូចតាច សង្ហារឹម និង សំភារៈបរិក្ខារ " លេខ ៦០៥ " :**

គណនីនេះ បើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការទិញសំភារៈ សង្ហារឹម និង សំភារៈបរិក្ខារ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០៥ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញសំភារៈនិងបរិក្ខារ ទិញសង្ហារឹម ទិញសំភារៈប្រើប្រាស់ និងសំរាប់ទិញសំភារៈផ្សេងៗ ។

### ៣១-គណនី ទិញថាមពល និង ទឹក " លេខ ៦០៦ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ការប្រើប្រាស់ថាមពល និង ការប្រើប្រាស់ទឹក ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាកបានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦០៦ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើអគ្គីសនី ចំណាយលើថ្លៃទឹក និងសំរាប់ចំណាយលើការទិញថាមពលផ្សេងៗទៀត ។

### ៣២-គណនី ទិញសំភារៈផ្គត់ផ្គង់ផ្សេង ៗ " លេខ ៦០៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុកប ខ័ណ្ឌ លើការទិញផ្សេងៗ ទៀត ដែលពុំបានរៀបរាប់ខាងលើ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

### ៣៣-គណនី ចំណាយលើកិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស " លេខ ៦១១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ជូនទៅសហគ្រាស ក្រុមហ៊ុន ឬ អាជីវករដែលបានផ្តល់សេវាកម្ម ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**៣៤_គណនី ចំណាយលើការជួលមធ្យោបាយដឹកជញ្ជូន " លេខ ៦១២ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូន ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**៣៥_គណនី ចំណាយលើថ្លៃឈ្នួល និង បន្ទុក (អចលនវត្ថុ) " លេខ ៦១៣ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ថ្លៃឈ្នួលទីតាំង ស្នាក់ការរដ្ឋបាល ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**៣៦_គណនី សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក " លេខ ៦១៤ ":**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការបណ្តុះបណ្តាលបុគ្គលិក និងកិច្ចសន្យានៃអ្នកជំនាញការ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លុកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃ ការិយបរិច្ឆេទ ។

**៣៧-គណនី ចំណាយលើការថែទាំ និង ជួសជុល " លេខ ៦១៥ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុកលើការថែទាំ និងជួសជុល ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹក ប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លុកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃ ការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦១៥ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើការថែទាំដីធ្លី សួនច្បាររៀបចំជាជួរ ការថែទាំទីផ្សារ សត្តឃាតដ្ឋាន និងអាគារសាធារៈ ការថែទាំ និងជួសជុលផ្លូវលំ ស្ពាន និងប្រព័ន្ធលូ ការថែទាំបណ្តាញផ្សេងៗ ការថែទាំ និងជួសជុលឧបករណ៍ សំភារៈការិយាល័យ សំភារៈពិតមានវិទ្យា និង ទូរគមនាគមន៍ ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន និង ការថែទាំនិងជួសជុលសំភារៈឧបករណ៍បច្ចេកទេស ។

**៣៨-គណនី សោហ៊ុយធានារ៉ាប់រង " លេខ ៦១៦ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការបង់ សោហ៊ុយធានារ៉ាប់រងផ្សេងៗ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លុកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃ ការិយបរិច្ឆេទ ។

**៣៩-គណនី សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ " លេខ ៦១៧ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការ

សិក្សាពិសោធន៍ ការប្រើប្រាស់សេវា និង ការប្រើប្រាស់សិទ្ធិ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីលេខ ៦១៧ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើសោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង សំរាប់សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ ។

## ៤០-គណនី សោហ៊ុយដឹកជញ្ជូន " លេខ ៦១៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើសោហ៊ុយដឹកជញ្ជូនសំភារៈ និងទំនិញ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦១៨ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើសោហ៊ុយដឹកជញ្ជូនសំភារៈ និង ទំនិញ ។

## ៤១-គណនី ចំណាយលើបុគ្គលិកខាងក្រៅ " លេខ ៦២១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ប្រាក់បំណាច់ លាភការ របស់បុគ្គលិកពីខាងក្រៅ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីលេខ ៦២១ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើភ្នាក់ងារជាតិជាប់កិច្ចសន្យា ភ្នាក់ងារ

បរទេសជាប់កិច្ចសន្យា និងសំរាប់បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ ។

**៤២_គណនី ចំណាយលើទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ " លេខ ៦២២ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦២២ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយសោហ៊ុយទទួលភ្ញៀវជាតិ សោហ៊ុយទទួលភ្ញៀវបរទេស ប្រជុំ សិក្ខាសាលានិង សិក្ខាសីទ សោហ៊ុយពិធីបុណ្យ សំរាប់ចំណាយទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស សោហ៊ុយសំរាប់ការតាំងពិពណ៌ក្នុង និង ក្រៅប្រទេស និងសំរាប់ការឃោសនា និងផ្សព្វផ្សាយពត៌មានសាធារណៈ ។

**៤៣_គណនី សោហ៊ុយខាងសារពត៌មាន និង ឯកសារ " លេខ ៦២៣ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់ថ្លៃសារពត៌មាន និង ទិញឯកសារ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**៤៤_គណនី ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស " លេខ ៦២៤ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់សោហ៊ុយក្នុងប្រទេស ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦២៤ត្រូវចែកទៅជាអនុគណនី សំរាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសំរាប់សោហ៊ុយស្នាក់នៅ ។

**៤៥. គណនី ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស " លេខ ៦២៥ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់សោហ៊ុយដឹកជញ្ជូន ចំនាយបេសកកម្ម និង ចំណាយស្នាក់នៅក្រៅប្រទេស ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦២៥ ត្រូវចែកទៅជាអនុគណនី សំរាប់សាហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសំរាប់សោហ៊ុយស្នាក់នៅ ។

**៤៦. គណនី សោហ៊ុយទូរគមនាគមន៍ ទូរសព្ទ តេឡិច និងទូរសារប្រៃសណីយ៍ "លេខ ៦២៦"**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើការទូទាត់សេវាទូរគមនាគមន៍ ទូរស័ព្ទ និងទូរសារប្រៃសណីយ៍ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦២៦ ត្រូវចែកទៅជាអនុគណនី សំរាប់សោហ៊ុយប្រៃសណីយ៍ និង សំរាប់សោហ៊ុយទូរគមនាគមន៍ ។

**៤៧_គណនី សោហ៊ុយធនាគារ " លេខ ៦២៧ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើសេវាធនាគារ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**៤៨_គណនី សោហ៊ុយផ្សេង ៗ " លេខ ៦២៨ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការទូទាត់សោហ៊ុយផ្សេងៗ ទៀត ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៤៩_គណនី ចំណាយលើលតាប័ត្រ " លេខ ៦៣១ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការបង់ពន្ធលតាប័ត្រ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៥០_គណនី ចំណាយលើលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ " លេខ ៦៤១ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការ

ទូទាត់លាភការ និង ប្រាក់បំណាច់នៃអំណាចសាធារណៈ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦៤១ ត្រូវចែកទៅជាអនុគណនី សំរាប់ប្រាក់បំណាច់អភិបាលស្រុក ខ័ណ្ឌ និងសំរាប់ប្រាក់បំណាច់អភិបាលរងស្រុក ខ័ណ្ឌ ។

## ៥១_អនុគណនី ការសង និងការបង្វិលវិញនូវលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ " លេខ ៦៤១៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីការបង្វិលសងមកថវិកាស្រុក ខ័ណ្ឌ វិញនូវលាភការ និង ប្រាក់បំណាច់ ( ជាសំណេះចំណាយ ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានពីការបង្វិលសងមកដែលបានផ្ទេរកាត់កងជាមួយគណណីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការសង និង ការបង្វិលវិញនូវលាភការនិង ប្រាក់បំណាច់នៃអំណាចសាធារណៈ

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់បង្វិលសងដែលបានទទួលបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីចំណាយថវិកាពាក់ព័ន្ធ ។

**ចំណាំ** : គណនីលេខ ៦៤១៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់អនុគណនីចំណាយថវិកាពាក់ព័ន្ធ ដោយយកលេខចុងក្រោយរបស់អនុគណនីបន្ថែមពីក្រោយលេខអនុគណនី ៦៤១៩ ។

## ៥២_គណនី ចំណាយលើលាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍"លេខ ៦៤២ ":

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើលាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦៤២ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងបន្ថែម ប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ទទួលខុសត្រូវ និងប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព ។

## ៥៣_អនុគណនី ការសង និង ការបង្វិលវិញនូវប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ "លេខ ៦៤២៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលស្រុក ខ័ណ្ឌ បានមកពីការសង និងការបង្វិលវិញនូវប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ (ជាសំណេះចំណាយ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានពីការបង្វិលសងមកថវិកាវិញ ដែលបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលដែលបានពីការសងនិងការបង្វិលវិញនូវប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍

សមតុល្យ: ឥណទាយី បង្ហាញចំនួនទឹកប្រាក់ការសង និងការបង្វិលសងដែលបានទទួលបូកបន្ត ហើយពុំទាន់បានផ្ទេរទៅគណនីចំណាយថវិកាពាក់ព័ន្ធ ។

**ចំណាំ** : គណនីលេខ ៦៤២៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់អនុគណនីចំណាយថវិកាពាក់ព័ន្ធ ដោយយកលេខចុងក្រោយរបស់អនុគណនីបន្ថែមពីក្រោយលេខអនុគណនី ៦៤២៩ ។

## ៥៤_គណនី ចំណាយលើលាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត" លេខ ៦៤៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌលើលាភការ និង ប្រាក់បំណាច់ បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ :** គណនីលេខ ៦៤៤ ត្រូវចែកទៅជាអនុគណនី សំរាប់បៀវត្សជាមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ លាភការផ្សេងៗ ទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត និងសំរាប់លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត ។

**៥៥_អនុគណនី ការសង និងការបង្វិលវិញនូវលាភការ និងប្រាក់បំណាច់បុគ្គលិកអណ្តែត " លេខ ៦៤៤៩ " :**

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនប្រាក់លាភការ ប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត ដែលបានបង្វិលសងមកស្រុក ខ័ណ្ឌ វិញ ( ជាសំណោះចំណាយ ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានបង្វិលសងមក ដែលបានបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ពីការបង្វិលសងមកវិញនូវលាភការ និង ប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងវិញដែលបានទទួលបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីចំណាយថវិកាពាក់ព័ន្ធ ។

**ចំណាំ** : គណនីលេខ ៦៤៤៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់អនុគណនីចំណាយថវិកាពាក់ព័ន្ធ ដោយយកលេខចុងក្រោយរបស់អនុគណនីបន្ថែមពីក្រោយលេខអនុគណនី ៦៤៤៩ ។

**៥៦_គណនី ចំណាយលើប្រាក់វិភាជន៍សង្គម " លេខ ៦៤៥ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើប្រាក់វិភាជន៍សង្គម ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ :** គណនីលេខ ៦៤៥ ត្រូវចែកជាអនុគណនី សំរាប់ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន មរណៈភាព ឧបត្ថម្ភនិវត្តន៍ជន ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ គ្រោះថ្នាក់ការងារ និងទពលភាព ឧបត្ថម្ភឱសថដល់មន្ត្រីរាជការ និងសំរាប់ឧបត្ថម្ភផ្សេងៗ ។

**៥៧_អនុគណនី ការសង និងការបង្វិលវិញនូវប្រាក់វិភាជន៍សង្គម " លេខ ៦៤៥៩ " :**

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនប្រាក់វិភាជន៍សង្គមដែលបានបង្វិលសងមកថវិកាស្រុក ខ័ណ្ឌវិញ ( ជាសំណោះចំណាយ ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានបង្វិលសងមកថវិកាវិញ ដែលបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំនួលពីកាតបង្វិលសងវិញនូវប្រាក់វិភាជន៍សង្គមដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងដែលបានទទួលបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីចំណាយថវិកាពាក់ព័ន្ធ ។

__ចំណាំ__ : គណនីលេខ ៦៤៥៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់អនុគណនីចំណាយថវិកាពាក់ព័ន្ធ ដោយយកលេខចុងក្រោយរបស់អនុគណនីបន្ថែមពីក្រោយលេខអនុគណនី ៦៤៥៩ ។

**៥៨_គណនី ចំណាយឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី " លេខ ៦៥១ ":**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុងប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការឧបត្ថម្ភដល់រដ្ឋបាលដែនដី ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

__ចំណាំ__ : គណនីលេខ ៦៥១ ត្រូវចែកជាអនុគណនី សំរាប់ឧបត្ថម្ភកធនផ្តល់ទៅដល់ ឃុំ សង្កាត់ និងសំរាប់ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**៥៩_គណនី ចំណាយលើជំនួយសង្គម និង ប្រាក់វិភាជន៍ " លេខ ៦៥២ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ ជាជំនួយដល់ សង្គមកិច្ច និងប្រាក់វិភាជន៍ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តហើយពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦៥២ ត្រូវចែកជាអនុគណនី សំរាប់ជំនួយដល់ប្រជាជនក្រីក្រសំរាកពេទ្យ ជួយជនរងគ្រោះដោយធម្មជាតិ និងសំរាប់ចំណាយសង្គមផ្សេងៗទៀត ។

**៦០-គណនី ចំណាយឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គម និងវប្បធម៌"លេខ ៦៥៣ ":**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើការឧបត្ថម្ភដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈសង្គម និងវប្បធម៌ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ហើយពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**ចំណាំ** : គណនីលេខ ៦៥៣ ត្រូវចែកជាអនុគណនី សំរាប់ឧបត្ថម្ភមណ្ឌលកុមារកំព្រា ឧបត្ថម្ភសមាគមន៍កីឡា និងវប្បធម៌ និងសំរាប់ឧបត្ថម្ភកាកបាទក្រហម ។

**៦១-គណនី ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន" លេខ ៦៧១ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ស្រុក ខ័ណ្ឌ លើឥណទេយ្យ ឬ ចំណាយផ្សេងៗ ដែលបានជំរះ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

**៦២-គណនី តំលៃគណនេយ្យ នៃចំណែកសកម្មបានលក់ (តំលៃនៅសល់)" លេខ ៦៧៥ " :**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចាត់ជាចំណាយថវិកាស្រុក ខ័ណ្ឌ លើតំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) ក្រោយពីជំរះតំលៃអចលកម្ម និងចំនួនទឹកប្រាក់រំលស់បូកបន្ត។

**ការកត់ត្រា ៖**

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ ៖ ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៦៣-គណនី ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី " លេខ ៦៨១ " ៖**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាស្រុក ខ័ណ្ឌ លើ ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី ។

**ការកត់ត្រា ៖**

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ ៖ ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៦៤-គណនី ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី " លេខ ៦៨២ " ៖**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចាត់ជាចំណាយថវិកាស្រុក ខ័ណ្ឌ លើ ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី ។

**ការកត់ត្រា ៖**

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ ៖ ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៦៥-គណនី ផលពីការគ្រប់គ្រងរដ្ឋបាល " លេខ ៧៣២ " ៖**

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌដែលបាន មកការគ្រប់គ្រងរដ្ឋបាល ។

**ការកត់ត្រា ៖**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីការងាររដ្ឋបាលដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>**ចំណាំ**</u> : គណនីលេខ ៧៣២ ត្រូវចែកទៅជាអនុគណនី សំរាប់ សេវាសុរិយោដី សេវាសំណង់ ចំណូលសំរាប់ទំរង់ការរដ្ឋបាល ចំណូលពីការអនុញ្ញាតរដ្ឋបាល និងសំរាប់ចំណូលរដ្ឋបាល ផ្សេងៗទៀត ។

### ៦៦_គណនី ផលពីការជួលទ្រព្យសម្បត្តិអចលន៍ " លេខ ៧៣៣ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌ ដែលបានមកពីការជួលទ្រព្យសម្បត្តិជាអចលកម្មនានា ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបាន ផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីថ្លៃឈ្នួលទ្រព្យសម្បត្តិដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>**ចំណាំ**</u> : គណនីលេខ ៧៣៣ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណូលពីសត្តឃាតដ្ឋាន ការជួលកន្លែងលក់ដូរក្នុងទីផ្សារ ពីកំពង់ចំលង ពីយឿត្រី និងសំរាប់ភាស៊ីផ្សារ ។

### ៦៧_គណនី ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម " លេខ ៧៤១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌដែលបានមកពីប្រាក់ពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាបានពីការផាកពិន័យនិង ការដាក់ទណ្ឌកម្មដែលប្រមូលបាន និង ត្រូវប្រមូល

សមតុល្យ: ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

### ៦៨_គណនី ឧបត្ថម្ភសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិកាខេត្ត-ក្រុង " លេខ ៧៥១ "

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌ ដែលបាន

មកពីការឧបត្ថម្ភពីថវិកាខេត្ត-ក្រុង ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពី ឧបត្ថម្ភសំរាប់ដំណើរការ ដែលបានទទួលពីខេត្ត-ក្រុង

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

### ៦៩-គណនី ឧបត្ថម្ភសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការដ្ឋ "លេខ ៧៥២" :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌ ដែលបានមកពីការឧបត្ថម្ភដោយថវិការដ្ឋសំរាប់កិច្ចដំណើរការ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានពីបានមកពីឧបត្ថម្ភដោយថវិការដ្ឋ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកា បូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

### ៧០-គណនី ចំណូលឧបត្ថម្ភថវិកាពីប្រភពផ្សេងៗ "លេខ ៧៥៨" :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌ ដែលបានមកពីការឧបត្ថម្ភពីប្រភពផ្សេងៗ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានពីបានឧបត្ថម្ភពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកា បូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

### ៧១-គណនី ផលពីការលក់អចលកម្ម " លេខ ៧៧៥ " :

គណនីនេះ បើករតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្រុក ខ័ណ្ឌ ដែលបានមកពីការលក់អចលកម្មរូបី និង អចលកម្មរូបី ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការលក់អចលកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

**៧២-គណនី ការខាតនៃវិនិយោគ " លេខ ៧៨ " :**

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការផលិត សាងសង់អចលកម្មដោយស្រុក ខ័ណ្ឌ ផ្ទាល់ ហើយនៅដំណាច់ឆ្នាំត្រូវប្រមូលផ្តុំតួលេខកត់ត្រាលើគណនីនេះដើម្បី អោយមានតុល្យភាពជាមួយទឹកប្រាក់ចំណាយថវិកាពាក់ព័ន្ធការសាងសង់អចលកម្ម ។ គណនីនេះបដិភាគនឹងតំលៃ អចលកម្មដែលពាក់ព័ន្ធ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចាត់ជាចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ស្មើចំណាយថវិកាចរន្តតែមានការពាក់ព័ន្ធការវិនិយោគ

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់ចាត់ជាចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៚៚៚៚៚